# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ១២៥,៨៥៨ ដុល្លារអាមេរិក សម្រាប់គម្រោងសហគមន៍ថែទាំសុខភាពមូលដ្ឋានសម្រាប់មាតា និងទារក



ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ១២៥,៨៥៨ ដុល្លាអាមេរិក ដល់អង្គការមូលនិធិជប៉ុន-ភី. អេចស៍ ដើម្បីគាំទ្រគម្រោងសហគមន៍ថែទាំសុខភាពមូលដ្ឋានសម្រាប់មាតា និង ទារកនៅក្នុងខេត្តកំពង់ធំ (ដំណាក់កាលទី៣)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រី ហាយ៉ាស៊ុ អាសាកុ នាយិកាប្រចាំប្រទេសអង្គការមូលនិធិជប៉ុន - ភី . អេចស៍ នៅស្ថានទូតជប៉ុន។




ដោយបន្តសកម្មភាពពីដំណាក់កាលទីមួយ និងទីពីរ ក្នុងតំបន់គោលដៅ ស្រុកប្រតិបត្តិបារាយ៍-សន្ទុក ខេត្តកំពង់ធំនោះ ក្នុងដំណាក់កាលទី៣នេះ អង្គការមូលនិធិជប៉ុន - ភី . អេចស៍ នឹងបន្តធ្វើការបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តសុខភាព តាមសហគមន៍ដែលជាធនធានដ៏សំខាន់ក្នុងការលើកស្ទួយ និងផ្សព្វផ្សាយអំពីសេវាថែទាំសុខភាពមាតា និងទារកដល់ប្រជាជនក្នុងតំបន់។ អង្គការមូលនិធិជប៉ុន - ភី . អេចស៍ ក៏នឹងរៀបចំយុទ្ធនាការរស់នៅស្អាត ជួយសាងសង់បង្គន់អនាម័យនៅតាមផ្ទះ ព្រមទាំងគាំទ្រក្នុងការបង្កើតទំនាក់ទំនងល្អរវាងអ្នកស្ម័គ្រចិត្តសុខភាពតាមសហគមន៍ និងបុគ្គលិកក្នុងមណ្ឌលសុខភាព។ នៅពេលគម្រោងដំណាក់កាលទី៣នេះត្រូវបានបញ្ចប់ យើងរំពឹងថាប្រជាពលរដ្ឋប្រមាណ៤៧.000នាក់អាចអនុវត្តសេវាថែទាំសុខភាពមាតា និងទារក ព្រមទាំងការយល់ដឹងអំពីអនាម័យ និង ការថែទាំជាប្រចាំដោយខ្លួនឯងតាមរយៈបទពិសោធន៍ដែលទទួលបានពីគម្រោងនេះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ១៧,៩លានដុល្លាអាមេរិក ដល់គម្រោងចំនួន៧១ របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និង សកម្មភាពបោសសំអាតមីន។ គម្រោងរបស់អង្គការមូលនិធិជប៉ុន-ភី. អេចស៍នេះគឺជាគម្រោងទី១តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៣របស់ជប៉ុន (មេសា ២០១៣ ដល់ មិនា ២០១៤)



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*